

# ការឃ្លាំមើលសវនាការ

## សាលាដំបូងរាជធានី-ខេត្ត ( មករា ២០២២ - កក្កដា ២០២៣ )

**ភ្នំពេញ ថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ២០២៣**

Address: #3, St 158 Oukhna Trorung Kang, Boeng Raing, Saun Penh, Phnom Penh
Tel: (+855-23) 218 553/210 518/990 544
P.O Box: 1024 – P.O Box 20 at CCC
E-mail: info@adhoccambodia.org
Website: www.adhoccambodia.org
Facebook: www.facebook.com/adhoccam
Twitter: www.twitter.com/adhoccam

# មាតិកា

I. សេចក្តីផ្តើម ........ 3

II. ព័ត៌មានទូទៅ និងភាគីក្នុងរឿងក្តី ........ 4

III. សិទ្ធិក្នុងពេលជំនុំជម្រះ ........ 5

IV ការប្រតិបត្តិរបស់មេធាវី៖ ........ 8

V. អនុសាសន៍ ........ 10

## I. សេចក្តីផ្តើម

**អំពីសមាគមអាដហុក៖** សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា "សមាគមអាដហុក" ជាអង្គការក្រៅរដ្ឋាភិបាលមួយ ឯករាជ្យ អព្យាក្រឹត មិនរកផលចំណេញ និងមិនស្ថិតក្រោម ការឃុំគ្រងរបស់គណបក្សនយោបាយណាមួយឡើយ ។ សមាគមអាដហុក ជាអង្គការសិទ្ធិមនុស្សដំបូងគេដែលត្រូវបានបង្កើតឡើង នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៩១ នឹងត្រូវបានទទួលស្គាល់ជាផ្លូវការដោយសម្តេចព្រះ នរោត្តម សីហនុ ថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៩២ ព្រមទាំងចុះបញ្ជីក្រសួងមហាផ្ទៃ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០០ ប្រកាសលេខ២៧៨ ។

សមាគមអាដហុក ធ្វើសកម្មភាពមានវិសាលភាពទូទាំងប្រទេស ដែលមានស្នាក់ការកណ្តាល នៅរាជធានីភ្នំពេញ ព្រមទាំងមានស្នាក់ការសាខានៅតាមបណ្តាខេត្តគោលដៅចំនួន២១មាន៖ ១-ខេត្តព្រៃវែង ២-ខេត្តកំពង់ចាម ៣-ខេត្តក្រចេះ ៤-ខេត្តស្ទឹងត្រែង ៥-ខេត្តរតនគីរី ៦-ខេត្តមណ្ឌលគីរី ៧-ខេត្តកំពត ៨-ខេត្តកោះកុង ៩-ខេត្តព្រះសីហនុ ១០-ខេត្តកំពង់ធំ ១១-ខេត្តកំពង់ឆ្នាំង ១២-ខេត្តបាត់ដំបង ១៣-ខេត្តបន្ទាយមានជ័យ ១៤-ខេត្តឧត្តរមានជ័យ ១៥-ខេត្តសៀមរាប ១៦-ខេត្តព្រះវិហារ ១៧-ខេត្តកំពង់ស្ពឺ ១៨-ខេត្តពោធិ៍សាត់ ១៩-ខេត្តប៉ៃលិន ២០-ខេត្តស្វាយរៀង និង២១-ខេត្តត្បូងឃ្មុំ ។

សមាគមអាដហុក បានធ្វើការងារ ដើម្បីដោះស្រាយបញ្ហាពាក់ព័ន្ធនឹងសិទ្ធិមូលដ្ឋាន និងសិទ្ធិសេរីភាពមូលដ្ឋាននៅក្នុងប្រទេសកម្ពុជា តាមរយៈការផ្តល់ជូនប្រជាពលរដ្ឋនូវចំណេះដឹង និងការយល់ដឹងអំពីសិទ្ធិមនុស្ស ច្បាប់ លទ្ធិប្រជាធិបតេយ្យ របៀបការពារសិទ្ធិ និងសេរីភាពរបស់ខ្លួន ។ គោលបំណងចម្បងរបស់សមាគមអាដហុក គឺជួយជនរងគ្រោះពីការរំលោភបំពាន ឱ្យចេះស្វែងរកយុត្តិធម៌ ដោយខ្លួនឯង ពង្រឹងសមត្ថភាពរបស់ប្រជាពលរដ្ឋក្នុងការទាមទារសិទ្ធិរបស់ពួកគេ និងលើកទឹកចិត្តប្រជាពលរដ្ឋឱ្យបញ្ចុះបញ្ចូល ដើម្បីធ្វើការតស៊ូមតិលើកកម្ពស់ និងការកែលម្អច្បាប់ ស្ថាប័ននានា និងការអនុវត្តច្បាប់ឲ្យប្រសើរឡើង ដោយសន្តិវិធី ។

**វិធីសាស្ត្រ៖** របាយការណ៍ "ការឃ្លាំមើលសវនាការជំនុំជម្រះ" ត្រូវបានរៀបចំចងក្រងឡើងដោយបានប្រមូលព័ត៌មានតាមរយៈ របាយការណ៍ឃ្លាំមើលសវនាការ របស់មន្ត្រីបុគ្គលិក អ្នកសម្របសម្រួល ការិយាល័យសមាគមអាដហុក នៅតាមបណ្តាខេត្ត/រាជធានី ដែលមានវិសាលភាពអនុវត្តសកម្មភាពទូទាំងប្រទេស និងបានចូលរួមក្នុងសវនាការជំនុំជម្រះដោយផ្ទាល់ ។ ករណីទាំងអស់ដែលបុគ្គលិកសមាគមអាដហុក បានចូលរួមក្នុងសវនាការជំនុំជម្រះដោយផ្ទាល់ គឺជាករណីដែលស្ថិតនៅក្នុងអាណត្តិរបស់សាមាគម ហើយជាករណីដែលសមាគមអាដហុកបានផ្តល់មេធាវី ដើម្បីតំណាងដោយអាណត្តិការពារតាមផ្លូវច្បាប់តាមសំណើជនរងគ្រោះផងដែរ ។ ទម្រង់ឃ្លាំមើលសវនាការមាន១៩សំនួរ ត្រូវបានបង្កើតឡើងសំរាប់ប្រើប្រាស់ក្នុងពេលចូលរួមឃ្លាំមើលសវនាការជំនុំជម្រះ ហើយបញ្ជូនរបាយការណ៍នោះ មកស្នាក់ការកណ្តាលភ្នំពេញបញ្ចូលក្នុងទិន្នន័យដែលបានបង្កើត (កញ្ចប់ស្ថិតិវិទ្យាសាស្ត្រសង្គម ' SPSS ') ដើម្បីប្រើប្រាស់ក្នុងការធ្វើវិភាគ និងយកមកសរសេររបាយការណ៍នេះ ។

**គោលបំណង៖** របាយការណ៍" ការឃ្លាំមើលសវនាការជំនុំជម្រះ " ត្រូវបានធ្វើឡើង ដើម្បីចូលរួមចំណែកក្នុងការលើកកម្ពស់សិទ្ធិស្វែងរកយុត្តិធម៌ប្រកបដោយតម្លាភាព និងធានាភាពគ្មានអគតិទាំងបួន ជាពិសេសចូលរួមក្នុងការផ្តល់ព័ត៌មានដែលបានរកឃើញពាក់ព័ន្ធ ការប្រតិបត្តិវិស័យយុត្តិធម៌របស់ចៅក្រមតំណាងអយ្យការ និងមេធាវីក្នុងគោលបំណង ធ្វើឲ្យកាន់តែប្រសើរឡើងប្រព័ន្ធយុត្តិធម៌ក្នុងប្រទេសកម្ពុជា ។

## II. ព័ត៌មានទូទៅ និងនាគីក្នុងរឿងក្តី

របាយការណ៍ " **ការឃ្លាំមើលសវនាការ** " ធ្វើឡើងក្នុងវិសាលភាពត្រឹមកម្រិតអង្គជំនុំជម្រះសាលាដំបូងរាជធានី -ខេត្ត "តុលាការខេត្ត-រាជធានី" ដែលបានចូលរួមឃ្លាំមើលសវនាការ ចាប់ពីខែមករា ឆ្នាំ២០២២ ដល់ខែកក្កដា ឆ្នាំ២០២៣។

អំឡុងពេលរបាយការណ៍បុគ្គលិកសមាគមអាដហុក បានចូលរួមឃ្លាំមើលសវនាការជំនុំជម្រះ១៧៥ករណី នៅតាមបណ្តាសាលាដំបូងរាជធានី-ខេត្តចំនួន២០ ដែលមានមេធាវីតំណាងឲ្យសមាគមជាអ្នកតំណាងដោយអាណត្តិផ្លូវច្បាប់ដល់ជនរងគ្រោះផ្ទាល់ ដូចជាសាលាដំបូង៖ រាជធានីភ្នំពេញ ខេត្តបន្ទាយមានជ័យ មណ្ឌលគីរី ព្រះវិហារ ព្រៃវែង រតនៈគីរី សៀមរាប ព្រះសីហនុ ស្ទឹងត្រែង បាត់ដំបង ស្វាយរៀង តាកែវ ឧត្តរមានជ័យ ប៉ៃលិន ត្បូងឃ្មុំ កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ កំពត និងខេត្តកោះកុង។

ក្នុង១៧៥ករណី ដែលសមាគមអាដហុកបានចូលរួមឃ្លាំមើលនោះ មាន៧៩(៤៥.១%) ករណីស្ថិតក្នុងផ្នែកសិទ្ធិមនុស្ស ៦៤(៣៦.៦%)ករណីក្នុងផ្នែកសិទ្ធិស្ត្រី-កុមារ និង៣២(១៨.៣%)ករណីក្នុងផ្នែកសិទ្ធិដីធ្លីដែលភាគច្រើននៃករណីពាក់ព័ន្ធនឹងសកម្មជននយោបាយ សកម្មជនសិទ្ធិមនុស្ស និងករណីរំលោភសិទ្ធិដីធ្លី។

ក្នុង១៧៥ករណី ដែលសមាគមអាដហុកបានចូលរួមឃ្លាំមើលនោះដែរ ក៏មានករណីកម្រិតទោស បទឧក្រិដ្ឋចំនួន១៣៧ករណី និងបទមជ្ឈឹមចំនួន៣៨ករណី(បទលហុគ្មាន) ហើយដែលមានជនជាប់ចោទ/ចុងចម្លើយជាជនរងគ្រោះសរុបចំនួន១,១៦៥នាក់ (ស្ត្រីចំនួន១៥១នាក់ កុមារចំនួន០៩នាក់ ហើយក្នុងនោះអវត្តមានក្នុងពេលសវនាការចំនួន៣៥៨នាក់) និងដើមបណ្តឹងជាជនរងគ្រោះសរុបចំនួន៤៥២នាក់ (ស្ត្រីចំនួន៦៧នាក់កុមារចំនួន៣៦នាក់ ហើយក្នុងនោះអវត្តមានក្នុងពេលសវនាការចំនួន០៩នាក់) ។

**ការលើកពេលសវនាការ៖** ១៧៥ករណី ដែលសមាគមអាដហុក បានចូលរួមឃ្លាំមើលមាន៥១ករណីជំនុំជម្រះដោយចៅក្រមទោល និង១២៤ករណីដោយចៅក្រមក្រុមប្រឹក្សា ។ ហើយនៅក្នុងនោះ តុលាការបានលើកពេលសវនាការជំនុំជម្រះចំនួន៤៥ (២៥,៧%) ក្រោមមូលហេតុសមាសភាពចៅក្រមក្រុមប្រឹក្សាជាប់រវល់ តុលាការមានប្រជុំបន្ទាន់ មានការស្នើសុំពីមេធាវីជនជាប់ចោទ អវត្តមានមេធាវីដើមបណ្តឹង ពន្ធនាគារមិនបញ្ជូនជនជាប់ចោទ និងតុលាការត្រូវការភស្តុតាងបន្ថែម ។

**ការឃុំខ្លួនបណ្តោះអាសន្នលើ៦ខែ**[1]**៖** ១៧៥ករណី ដែលសមាគមអាដហុកបាន ចូលរួមឃ្លាំមើល មាន១៤២ករណី ដែលជនជាប់ចោទត្រូវបានតុលាការសំរេចឃុំខ្លួនបណ្តោះអាសន្ន។ ហើយយោង តាមរបាយការណ៍បានបង្ហាញថា បើគិតមកដល់ថ្ងៃបើកសវនាការ ការឃុំខ្លួនបណ្តោះអាសន្ន ដែលមានថេរវេលាលើសពី៦ខែហូតដល់ជាង២៤ខែមានចំនួន៨០ករណី នៃ១៧៥ករណី ដូចជា៖

- ចន្លោះពីលើស៦ ដល់ ៩ខែ ចំនួន៣៤ ករណី
- ចន្លោះពី១០ ដល់ ១២ខែ ចំនួន១២ ករណី
- ចន្លោះពី១៨ ដល់ ២៣ខែ ចំនួន០២ ករណី
- ចន្លោះពី២៤ ឡើងលើ ចំនួន៣២ ករណី

[1] មាត្រា២០៨ មាត្រា២០៩ មាត្រា២៤៩ មាត្រា២៨៣ និងមាត្រា៣០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ និងមាត្រា១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

**ភាពខុសគ្នារវាងពេលវេលាបានកំណត់ក្នុងដីកា និងពេលវេលាបើសវនាការជំនុំជម្រះជាក់ស្តែង៖** យោងតាមរបាយការណ៍ក៏បានបង្ហាញឲ្យឃើញជាច្រើនករណីផងដែរថា មានភាពខុសគ្នាច្រើន រវាងពេលវេលាដែលបានកំណត់នៅក្នុងដីកា និងពេលវេលានៃដំណើរការបើកសវនាការជំនុំជម្រះជាក់ស្តែង ភាពខុសគ្នានោះមានរហូតដល់យ៉ាងតិចមួយម៉ោង ឬមួយម៉ោងកន្លះ ទៅពីម៉ោងដូចជា ម៉ោងបានកំណត់ក្នុងដីកា ៨:០០ព្រឹកជាកំហិត ប៉ុន្តែម៉ោងបើកសវនាការជាក់ស្តែង យ៉ាងតិច៩:០០ព្រឹក ទៅ៩:៣០ ឬម៉ោង១០:០០ ហើយជួនកាលដល់ម៉ោង១១:០០ផងក៏មាន។

## III. សិទ្ធិក្នុងពេលជំនុំជម្រះ

**សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ**[2] យោងតាមរបាយការណ៍ ស្រាវជ្រាវបានបង្ហាញថា មាន១០៣ករណី(៥៩%)នៃ១៧៥ករណី តុលាការមិនបានជូនដំណឹង អំពីសវនាការ ដោយមិនបានបិទផ្សាយនៅលើក្តារខៀនព័ត៌មានខាងក្រៅបន្ទប់សវនាការឡើយ ។ លើសពីនេះទៀត ក្នុងចំណោម១៧៥ករណី មានសាធារណៈជន និងអ្នកសារព័ត៌មានត្រូវបានរាំងមិនឲ្យចូល ឬបណ្តេញចេញពីបន្ទប់សវនាការ៖

<table>
<tr><th colspan="2">ការរាំងមិនឲ្យចូល ឬបណ្តេញចេញពីបន្ទប់សវនាការ</th></tr>
<tr><td>សាធារណៈជន (១៤២ករណី - ៨១.១៤%)</td><td>អ្នកសារព័ត៌មាន (១១៦ករណី - ៦៦.២៨%)</td></tr>
<tr><td colspan="2">មូលហេតុ៖<br>- បន្ទប់សវនាការតូចចង្អៀត គ្មានកៅអីអង្គុយគ្រប់គ្រាន់<br>- គ្មានដីកាអញ្ជើញ ឬមិនបានចុះឈ្មោះជាមុន<br>- នគរបាលបិទទ្វាររបងមិនអនុញ្ញាតឲ្យចូល<br>- តុលាការជំនុំជម្រះរឿងក្តីឯកជនដូចជាករណីរំលោភ និងករណីអនីតិជន</td></tr>
</table>

**សិទ្ធិដឹងពីមូលហេតុ និងបទចោទប្រឆាំងខ្លួន**[3]**៖** របាយការណ៍ស្រាវជ្រាវបានបង្ហាញថា មានចន្លោះពី៣៤% ដល់៥០.៨៥% នៃ១៧៥ករណី នៅក្នុងសវនាការជំនុំជម្រះ តុលាការ(ចៅក្រម) នៅតែមិនបានអនុវត្តឲ្យបានពេញលេញនូវសិទ្ធិរបស់ជនជាប់ចោទដឹងពីមូលហេតុ និងបទចោទប្រឆាំងនឹងខ្លួនឡើយ៖

| **សិទ្ធិដឹងពីមូលហេតុ និងបទចោទ (សរុប ១៧៥ករណី)** | **ប្រាប់ទាំងអស់ (ករណី)** | **ប្រាប់ខ្លះៗ (ករណី)** | **ជាភាគរយ (%)** |
|---|---|---|---|
| ប្រាប់ពីបទចោទដែលពាក់ព័ន្ធដល់ជនជាប់ចោទគ្រប់រូប | ៨៦ | ៨៩ | ៥០.៨៥ |
| ប្រាប់ពីមាត្រាច្បាប់ពាក់ព័ន្ធ | ១០២ | ៧៣ | ៤១.៧១ |
| ប្រាប់ពីកាលបរិច្ឆេទប្រព្រឹត្តបទល្មើស | ១១៥ | ៦០ | ៣៤.២៨ |
| ប្រាប់ពីទីកន្លែងប្រព្រឹត្តបទល្មើស | ១១៦ | ៥៩ | ៣៣.៧១ |
| ប្រាប់ពីភាគីពាក់ព័ន្ធនានាក្នុងបទល្មើស | ៩២ | ៨៣ | ៤៧.៤២ |
| ប្រសិនបើត្រូវការតុលាការបានផ្តល់អ្នកបកប្រែ | ១០៦ | ៦៩ | ៣៩.៤២ |

[2] មាត្រា ៣១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[3] មាត្រា ៣២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

**ការពន្យល់ប្រាប់ពីសិទ្ធិរបស់ជនជាប់ចោទ៖** នៅក្នុងពេលជំនុំជម្រះ ចៅក្រមហាក់បីដូចជា មិនសូវយកចិត្តទុកដាក់ក្នុងការពន្យល់ប្រាប់សិទ្ធិជនជាប់ចោទ អំពីសិទ្ធិដែលពួកគេត្រូវទទួលបាន ។ លទ្ធផលស្រាវជ្រាវបានបង្ហាញ ទិន្នន័យចន្លោះពី១១% និង ៣៧% នៃ១៧៥ករណី ចៅក្រមខកខានមិនបានពន្យល់ប្រាប់ជនជាប់ចោទអំពីសិទ្ធិមួយចំនួនដូចជាៈ សិទ្ធិមានមេធាវី ឬសិទ្ធិការពារខ្លួន សិទ្ធិមិនឆ្លើយ សិទ្ធិមិនបង្ខំឲ្យសារភាពកំហុស និងសិទ្ធិការសន្មត់ទុកជាមុនថា គ្មានកំហុស យ៉ាងណាមិញ យោងតាមទិន្នន័យ មានរហូតដល់ពីចន្លោះ៤០% ដល់៥៤% នៃ១៧៥ករណី ចៅក្រមគ្រាន់តែប្រាប់ត្រួសៗអំពីសិទ្ធិដែលជនជាប់ចោទត្រូវមានដោយមិនបានពន្យល់ក្បោះក្បាយឡើយ។

| ចៅក្រមបានប្រាប់ និងពន្យល់ជនជាប់ចោទអំពី (សរុប ១៧៥ករណី) | ប្រាប់និងពន្យល់ (ករណី) | គ្រាន់តែប្រាប់ (ករណី) | មិនប្រាប់-មិនពន្យល់ (ករណី) |
|---|---|---|---|
| សិទ្ធិមានមេធាវី ឬសិទ្ធិការពារខ្លួន[4] | ៨៧ | ៦៩ (៤០%) | ១៩ (១១%) |
| សិទ្ធមិនឆ្លើយ | ៣៨ | ៩៥ (៥៤%) | ៤២ (២៤%) |
| សិទ្ធិមិនបង្ខំឲ្យសារភាពកំហុស | ៣២ | ៩៤ (៥៤%) | ៤៩ (២២%) |
| សិទ្ធិការសន្មត់ទុកជាមុនថាគ្មានកំហុស | ១៧ | ៩៤ (៥៤%) | ៦៤ (៣៧%) |

**សិទ្ធិហៅ និងសួរសាក្សី៖**

សាក្សីនៅក្នុងរឿងក្ដី ១០៥ករណី (៦០%) នៃ១៧៥ករណី ត្រូវបានតុលាការកោះហៅ និងស្ថិតក្នុងបន្ទប់សវនាការអំឡុងពេលសាកសួរ ហើយក្នុងនោះបើតាមការសង្កេត នៅតែឃើញមានភាពមិនប្រក្រតិបានកើតឡើងដូចជាៈ មាន១៩ករណី (១១%) នៃ១៧៥ករណី សាក្សីដាក់បន្ទុកត្រូវបានតុលាការយកចិត្តទុកដាក់ជាងសាក្សីដោះបន្ទុក ចំណែកសាក្សីដោះបន្ទុក មាន៦ករណី (៣.៤២%) ដែលតុលាការយកចិត្តទុកដាក់ជាងសាក្សីដាក់បន្ទុក។

- ៦ករណី (៣.៤២%) នៃ១៧៥ករណី ភាគីជនជាប់ចោទត្រូវបានហាមឃាត់ មិនឲ្យបង្ហាញភស្តុតាងជាឯកសារ រួមទាំងចម្លើយរបស់សាក្សី។
- ១៧ករណី (៩.៧១%) នៃ១៧៥ករណី ក្នុងសវនាការជំនុំជម្រះ តុលាការ មិនអនុញ្ញាតឲ្យភាគីជនជាប់ចោទ និងមេធាវីរបស់ជនជាប់ចោទសាកសួរសាក្សី ឬភាគីដើមបណ្ដឹង ឬមេធាវីដើមបណ្ដឹង។

**សិទ្ធិនៅអំឡុងពេលសួរចម្លើយ និងការហាមឃាត់ការធ្វើទារុណកម្ម[5]៖** យោងតាមរបាយការណ៍ បានបង្ហាញថាអំឡុងពេលសួរចម្លើយ នៅតំណាក់កាលនគរបាលយុត្តិធម៌ ០៧ នៃ១៧៥ករណី មានការគំរាមកំហែងឲ្យសារភាព និងផ្ដិតមេដៃលើរបាយការណ៍ ជាពិសេសករណីគ្រឿងញៀន និង ០៣ករណីផ្សេងទៀត ជនជាប់ចោទត្រូវបាននគរបាលយុត្តិធម៌ ថ្នាក់ស្រុកដាក់ខ្នោះដៃ ធ្វើទារុណកម្មបង្ខំឲ្យសារភាព។

[4] មាត្រា៣០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[5] មាត្រា១ នៃអនុសញ្ញាប្រឆាំងទារុណកម្ម និងមាត្រា៥ នៃសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស និងមាត្រា១៤ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធនយោបាយ និងមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា

| ជនជាប់ចោទត្រូវបាន (សរុប១៧៥ករណី) | មិនមាន | មាន | បញ្ជាក់មូលហេតុ (មាន) |
|---|---|---|---|
| សួរចម្លើយដោយគ្មានវត្តមានមេធាវី | ១៦១ | ១៤ | ជនជាប់ចោទទើបស្នើសុំមេធាវីនៅដំណាក់កាលចៅក្រមស៊ើប |
| គំរាមកំហែងឲ្យសារភាព (ករណីគ្រឿងញៀន) | ១៦៨ | ០៧ | ជនជាប់ចោទបានប្រាប់ថាៈ នគរបាលបង្ខំឲ្យសារភាព និងផ្តិតមេដៃលើរបាយការណ៍ |
| ទទួលរងអំពើហិង្សា ឬទារុណកម្មបង្ខំឲ្យសារភាព | ១៧២ | ០៣ | ជនជាប់ចោទបានប្រាប់ថាៈ នគរបាលស្រុកដាក់ខ្នោះដៃ បង្ខំឲ្យសារភាព |

**ការសន្មត់ទុកជាមុនថាគ្មានទោស**[6] ៖ យោងតាមរបាយការណ៍ បានបង្ហាញថាមាន ៤៦.២៨%(៨១ករណីនៃ១៧៥ករណី) ចៅក្រមជំនុំជម្រះ និយាយពីភាពមានពិរុទ្ធរបស់ជនជាប់ចោទមុនពេលចេញសាលក្រមដោយចៅក្រម "បានប្រាប់ឲ្យជនជាប់ចោទសុំទោស" លើសពីនេះទៀត មាន០៧ករណី ចៅក្រមទាញពិរុទ្ធភាពពីការនៅស្ងៀមរបស់ជនជាប់ចោទ ទន្ទឹមគ្នានោះដែរ ព្រះរាជអាជ្ញាស្រែកសម្លុតនៅពេលជនជាប់ចោទរក្សាសិទ្ធិមិនឆ្លើយ។ នៅក្នុងនោះ មាន ៧៥.៤២% (១៣២ករណី នៃ១៧៥ករណី) ជនជាប់ចោទ បង្ហាញខ្លួននៅអំឡុងពេលសវនាការក្នុងឯសណ្ឋានពន្ធនាគារ និង ៤១.១៤% (៧២ករណី នៃ១៧៥ករណី) ជនជាប់ចោទត្រូវបានដាក់ខ្នោះដៃក្នុងអំឡុងពេលសវនាការ។

| ជនជាប់ចោទបង្ហាញខ្លួន (សរុប១៧៥ករណី) | មិនមាន | មាន | បញ្ជាក់មូលហេតុ (មាន) |
|---|---|---|---|
| អំឡុងពេលសវនាការក្នុងឯកសណ្ឋានពន្ធនាគារ | ៤៣ | ១៣២ | |
| ជាប់ខ្នោះក្នុងអំឡុងពេលសវនាការ | ១០៣ | ៧២ | ជនជាប់ចោទដៃជាប់ខ្នោះនៅពេលរងចាំសវនាការ ប៉ុន្តែពេលឡើងក្រចកសេះ ត្រូវបានដោះខ្នោះចេញវិញ |
| ចៅក្រមបាននិយាយពីភាពមានឬគ្មានទោសជនជាប់ចោទមុនពេលចេញសាលក្រម | ៩៤ | ៨១ | ចៅក្រមជំនុំជម្រះបានប្រាប់ឲ្យជនជាប់ចោទសុំទោស |
| ចៅក្រមទាញពិរុទ្ធភាពពីការនៅស្ងៀមរបស់ជនជាប់ចោទ | ១៦៨ | ០៧ | ព្រះរាជអាជ្ញាស្រែកសម្លុត នៅពេលជនជាប់ចោទមិនឆ្លើយ |

[6] មាត្រា៣៨ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា និងមាត្រា១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងមាត្រា១១ នៃសេចក្តីប្រកាសស្តីពីសិទ្ធិមនុស្ស

## IV ការប្រតិបត្តិរបស់មេធាវី ៖

- ៨៨% (១៥៤ នៃ១៧៥ករណី) មេធាវីតំណាងដោយអាណត្តិ មានវត្តមាន អំឡុងពេលសវនាការ លើកលែងតែ១៦ករណី ប៉ុណ្ណោះដែលសវនាការប្រព្រឹត្តដោយគ្មានមេធាវី ដោយសារជនរងគ្រោះជាដើមបណ្តឹងរដ្ឋប្បវេណីមិនបានស្នើសុំមេធាវី ។ ហើយនៅក្នុងនោះមាន៦០% (១០៥នៃ១៥៤ករណីដែលមានមេធាវី) ជាមេធាវីតំណាងឲ្យជនជាប់ចោទលើសពីម្នាក់ "មេធាវីម្នាក់ការពារឲ្យជនជាប់ចោទមួយក្រុមដែលភាគច្រើន គឺជាតំណាងសហគមន៍វិវាទដីធ្លី ធនធានធម្មជាតិ និងសេរីភាពមូលដ្ឋាន"។

- ៥៨.៣% (១០២ នៃ១៧៥ករណី មេធាវី បានលើកឡើងអំពីសិទ្ធិទទួលបាន ការជំនុំជម្រះដោយយុត្តិធម៌របស់កូនក្តីរបស់ខ្លួន ដូចជាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ សិទ្ធិដឹងពីបទចោទ និងសិទ្ធិមានវត្តមានពេលសវនាការ ។
- មានត្រឹមតែ៩.១៤%(១៦នៃ១៧៥ករណី) មេធាវី បាននិយាយយោងច្បាប់អន្តរជាតិក្នុងពេលសវនាការ ដូចជាសេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិ ស្តីអំពីសិទ្ធិស៊ីវិល និងសិទ្ធិនយោបាយ ជាដើម។
- មានត្រឹមតែ ២៩.១៤% (៥១ នៃ១៧៥ករណី) មេធាវី បានលើកឡើងអំពីភាពមិនពេញលេញ និងមិនស៊ីសង្វាក់នៃភស្តុតាង។
- មានត្រឹមតែ ៦.៣ (១១ នៃ១៧៥ករណី) មេធាវីបានប្រើទូរស័ព្ទដៃនៅក្នុងពេលសវនាការ
- មានត្រឹមតែ ២.៩% (៥ នៃ១៧៥ករណី) មេធាវីបានដើរចេញពីបន្ទប់សវនាការ

**ឯករាជ្យភាព ភាពមិនលំអៀង និងការប្រព្រឹត្តរបស់ចៅក្រមលើភាគីពាក់ព័ន្ធ ៖** យោងតាមរបាយការណ៍ បានបង្ហាញថា មាន១៨.៨៥% (៣៣ នៃ១៧៥ករណី) ចៅក្រម និង តំណាងអយ្យការ បានប្រើប្រាស់ទូរស័ព្ទដៃអំឡុងពេលសវនាការ និង ៤៦.៨៥% ដើរចាកចេញពីបន្ទប់សវនាការ ដោយមូលហេតុចៅក្រមមានសវនាការច្រើន ឬទៅបន្ទប់ទឹកជាដើម។ ១០.៣% ដែលចៅក្រម និងតំណាងអយ្យការ នៅតែសម្តែងអាកប្បកិរិយាសម្លុតគំរាមដល់ជនជាប់ចោទអំឡុងពេលសវនាការដូចជា ឲ្យជនជាប់ចោទសារភាព ទាញទូរស័ព្ទដើម្បីថតសម្លេង និងស្រែកសម្លុតជនជាប់ចោទ ។ ៣.៤២% ដែលចៅក្រម និងតំណាងអយ្យការ បានប្រើពាក្យពេជន៍បែបរើសអើងទៅកាន់ជនជាប់ចោទជាជាតិពន្ធ និងហាមប្រាមមិនឲ្យស្លៀកសំលៀកបំពាក់ប្រពៃណីជាដើម ។

| ចៅក្រម/តំណាងអយ្យការបាន (សរុប១៧៥ករណី) | មិនមាន | មាន | បញ្ជាក់មូលហេតុ (មាន) |
|---|---|---|---|
| សម្តែងអាកប្បកិរិយា សម្លុតគំរាមដល់ភាគីជនជាប់ចោទ | ១៥៧ | ១៨ | - ឲ្យជនជាប់ចោទសារភាព<br>- ទាញទូរស័ព្ទដើម្បីថតសម្លេង<br>- ប្រើពាក្យសម្តីមិនសមរម្យ ស្រែកសម្លុតដាក់ជនជាប់ចោទ |
| ប្រើពាក្យពេជន៍បែបរើសអើងទៅកាន់ភាគីជនជាប់ចោទ | ១៦៩ | ០៦ | - ប្រាប់មិនឲ្យស្លៀកសំលៀកបំពាក់អប្បរា<br>- ទៅលើជនជាប់ចោទជាតិពន្ធ |

| | | | |
|---|---|---|---|
| ចាកចេញពីបន្ទប់អំឡុងពេលសវនាការ | ៩៣ | ៨២ | - ចៅក្រមមានសវនាការច្រើន<br>- ទៅបន្ទប់ទឹក<br>- មិនយកចិត្តទុកដាក់កិច្ចការរបស់ខ្លួន |
| ប្រើទូរស័ព្ទអំឡុងពេលសវនាការ | ១៤២ | ៣៣ | - ៦៦.៧% ចៅក្រម និង ៣៣.៣% តំណាងអយ្យការ<br>- ៦៦.៧% គ្រាន់តែឆ្លើយតបទូរស័ព្ទខ្លី ហើយដាក់ចុះវិញ<br>- ៣៣.៣% និយាយសន្ទនា |

**ការពិភាក្សាសម្រេចរបស់តុលាការ៖** មាន៦.៣% (១១ នៃ១៧៥ករណី) ចៅក្រមបានធ្វើការពិភាក្សាសម្រេចអំឡុងពេលការពិភាក្សា សម្រេចរបស់ចៅក្រម និង ៩៧.៧% ចៅក្រមមិនបានពិភាក្សាសម្រេចអំឡុងពេលការពិភាក្សាសម្រេចរបស់ចៅក្រម។ ហើយមានត្រឹមតែ ២.៨៥% (៥ នៃ១៧៥ករណី) ដែលសាលក្រមត្រូវបានប្រកាសនៅថ្ងៃសវនាការ និង៩៧.១៥% ករណីត្រូវបានតុលាការលើកពេលប្រកាសសាលក្រម ហើយក្នុងនោះមាន៥៣.៧១% (៩៤ ករណី) តុលាការ លើកពេលប្រកាសសាលក្រម ដោយមិនបានបញ្ជាក់អំពីកាលបរិច្ឆេទច្បាស់លាស់ ។

**សាលក្រម៖** យោងតាមរបាយការណ៍បានបង្ហាញថា មាន៧៨.៣% (១៣៧ នៃ១៧៥ករណី) ចៅក្រមបាន បន្ថែមបទល្មើសថ្មីនៅពេលប្រកាសសាលក្រម និង មាន ៧.៤២% ចៅក្រមបានយោងមាត្រាច្បាប់ដែលជនជាប់ចោទត្រូវបានកាត់ទោស។

| **ចៅក្រមបាន (សរុប១៧៥ករណី)** | **មិនមាន** | **មាន** | **ភាគរយៈ (មាន)** |
|---|---|---|---|
| យោងមាត្រាច្បាប់ដែលជនជាប់ចោទត្រូវបានកាត់ទោស | ១៣ | ១៦២ | ៩២.៦% |
| បង្ហាញភស្តុតាងដែលនាំឲ្យមានការសម្រេចផ្តន្ទាទោស | ១៧៣ | ០២ | ១.១៤% |
| ផ្លាស់ប្តូរបទចោទលើជនជាប់ចោទនៅពេលប្រកាសសាលក្រម | ១៧៤ | ០១ | ០.៨% |
| បន្ថែមបទល្មើសថ្មីនៅពេលប្រកាសសាលក្រម | ៣៨ | ១៣៧ | ៧៨.៣% |

**យោងរបាយការណ៍ពីមេធាវីតំណាងឲ្យកូនក្តីផ្ទាល់៖**

- **ការមិនអនុញ្ញាតឲ្យសាក្សីដោះបន្ទុកចូលធ្វើសក្ខីកម្មបញ្ជាក់៖** ចៅក្រមជំនុំជម្រះ មិនអនុញ្ញាតឲ្យ-មិនកោះហៅ សាក្សីដោះបន្ទុក ដែលមេធាវីបានដាក់ស្នើតាំងពីតំណាក់កាលស៊ើបសួរ និងតំណាក់កាលជំនុំជម្រះ។ កាលបើតុលាការ ប្រើតែកំណត់ហេតុ របស់មន្ត្រីនគរបាលយុត្តិធម៌តែម្ខាង នោះអាចប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិការពារខ្លួនរបស់ជនជាប់ចោទ (ជាពិសេសករណីវិវាទដីធ្លីសមូហភាព)នៅ

ចំពោះមុខច្បាប់ប្រឆាំង នឹងការចោទប្រកាន់ណាមិនត្រឹមត្រូវ (បើយោងមាត្រា ១១០ និង ១១៨ និង មាត្រា៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ) ។

- **ការចេញលិខិតអញ្ជើញមេធាវីចូលសវនាការៈ** តុលាការបានចេញលិខិតអញ្ជើញមេធាវី ចូលរួមសវនាការយឺតយ៉ាវ ភាគច្រើន លិខិតអញ្ជើញមកដល់ត្រឹមតែមួយថ្ងៃ ឬពីរថ្ងៃមុនពេលសវនាការប៉ុណ្ណោះ ។ បើយោង មាត្រា ៤៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចំពោះរឿងក្តីព្រហ្មទណ្ឌ បើសំណុំរឿងស្ថិតក្នុងដៃព្រះរាជអាជ្ញា និងចៅក្រមជំនុំជម្រះ និង មាត្រា ២៣៦, ២៣៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌបើស្ថិតក្នុងដៃចៅក្រមស៊ើបវិញ ។
- ជាច្រើនករណី តុលាការមិនបានអញ្ជើញ មេធាវីចូលរួមអមកូនក្តី ដើម្បីស្តាប់ចម្លើយកូនក្តីនៅតំណាក់កាលព្រះអាជ្ញានោះទេ ។
- ជាង៩០% តុលាការ មិនបានជូនដំណឹងអំពីដីកាសម្រេច ដូចជា ដីកាសន្និដ្ឋានស្ថាពរ ដីកាដំណោះស្រាយ ។ (បើយោងមាត្រា ២៣៦ និងមាត្រា២៣៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)
- តុលាការពេលខ្លះកោះហៅកូនក្តី មិនអញ្ជើញមេធាវី ប៉ុន្តែបើបានអញ្ជើញមេធាវី មិនកោះហៅកូនក្តីចូលរួមនៅតំណាក់កាលព្រះរាជអាជ្ញា តំណាក់កាលចៅក្រមស៊ើបសួរ ។

## V. អនុសាសន៍

1. ក្រសួងយុត្តិធម៌ ពិនិត្យដាក់វិធានការណ៍ច្បាស់លាស់ ចំពោះការអនុវត្តន៍របស់ចៅក្រម និងតំណាងអយ្យការ ទាំងឡាយណា ដែលផ្ទុយនឹងគោលបំណង មាត្រា២០៨ និងមាត្រា២០៩ នៃនីក្រមតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ បានចែងអំពីថេរវេលា នៃការឃុំខ្លួនបណ្តោះអាសន្ន ។ បើយោងរបាយការណ៍បានបង្ហាញថា ការឃុំខ្លួនបណ្តោះអាសន្ន ដែលមានថិរវេលាលើសពី៦ខែ រហូតដល់ជាង២៤ខែមានចំនួន៨០ករណី នៃករណីសរុប១៧៥ ។
2. ក្រសួងយុត្តិធម៌ពិនិត្យ និងដាក់ពិន័យរដ្ឋបាលធ្ងន់ធ្ងរដល់ចៅក្រម និងតំណាងអយ្យការដែលមានការយឺតយ៉ាវចំពោះពេលវេលាបំពេញភារកិច្ចការងារ បើកសវនាការជំនុំជម្រះ ។ យោងតាមរបាយការណ៍បានបង្ហាញថា មានភាពយឺតយ៉ាវខ្លាំងពីជាងមួយម៉ោង រហូតដល់ពីរម៉ោង បើប្រៀបធៀបម៉ោងពេលបានកំណត់ក្នុងដីកា និងម៉ោងពេលបើកសវនាការជាក់ស្តែង។
3. ក្រសួងយុត្តិធម៌ ពិនិត្យដាក់វិធានការណ៍ច្បាស់លាស់ ចំពោះការអនុវត្តន៍របស់ចៅក្រម និងតំណាងអយ្យការទាំងឡាយណា ដែលមានការយឺតយ៉ាវក្នុងការចេញលិខិតអញ្ជើញមេធាវី និងភាគីចូលរួមក្នុងសវនាការជំនុំជម្រះ ។
4. ក្រសួងយុត្តិធម៌ ពិនិត្យដាក់វិធានការណ៍ច្បាស់លាស់ ចំពោះការអនុវត្តន៍របស់ចៅក្រម និងតំណាងអយ្យការទាំងឡាយណាដែលខកខាន មិនបានអញ្ជើញមេធាវីចូលរួមអមកូនក្តី ដើម្បីស្តាប់ចម្លើយកូនក្តីនៅតំណាក់កាលព្រះអាជ្ញា និងចៅក្រម ស្របតាមនីតិវិធី ។
5. ក្រសួងយុត្តិធម៌ ពិនិត្យដាក់វិធានការណ៍ច្បាស់លាស់ ចំពោះការអនុវត្តន៍របស់ចៅក្រម និងតំណាងអយ្យការទាំងឡាយណាដែលខកខានមិនបានជូនដំណឹងអំពីដីកាសម្រេចដូចជាដីកាសន្និដ្ឋានស្ថាពរ និងដីកាដំណោះស្រាយ ។
6. ចៅក្រម-តំណាងអយ្យការ ពិចារណាក្នុងការប្រើពាក្យ ឬនិយាយពីភាពមានឬគ្មានទោសដល់ជនជាប់ចោទ មុនពេលចេញសាលក្រម ជាពិសេសដូចជា ប្រាប់ឲ្យជនជាប់ចោទសុំទោស ។

7. ចៅក្រមពិនិត្យ-ពិចារណា អំពីសិទ្ធិរបស់ជនជាប់ចោទដូចជា ជនជាប់ចោទមានពាក់ឯកសណ្ឋានពន្ធនាគារ និងដៃជាប់ខ្នោះ ក្នុងអំឡុងពេលសវនាការជំនុំជម្រះ ។
8. ចៅក្រមពន្យល់ប្រាប់ជនជាប់ចោទ-ជនរងគ្រោះ ឲ្យបានច្បាស់លាស់ អំពីសិទ្ធិដែលត្រូវទទួលបានដូចជា សិទ្ធិមានមេធាវី សិទ្ធិមិនឆ្លើយ សិទ្ធិមិនបង្ខំឲ្យសារភាពកំហុស និងសិទ្ធិសន្មត់ទុកជាមុនថា គ្មានកំហុស សិទ្ធិដឹងពីបទចោទ សិទ្ធិដឹងការបរិច្ឆេទ-ទីកន្លែងប្រព្រឹត្តបទល្មើសជាដើម ។
9. ក្រសួងយុត្តិធម៌ ពិនិត្យដាក់វិធានការណ៍ច្បាស់លាស់ ចំពោះគ្រប់សាលាដំបូង ក្នុងការបើកចំហរដល់សាធារណៈជន និងអ្នកសារព័ត៌មានបានចូលស្តាប់សវនាការសាធារណៈ ដោយគ្មានការហាមឃាត់ និងបណ្តេញចេញ ។

**- ចប់ -**